**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកែប**
សំណុំរឿងព្រហ្មទណ្ឌលេខ ៤២ ចុះថ្ងៃទី
០៣ ខែមេសា ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌលេខ ១៥ (យ)
ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកែប

បានបើកសវនាការពិភាក្សាដេញដោលចំពោះមុខជាសាធារណៈ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោងប្រាំបី និងសាមសិប នាទីព្រឹក

ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកែប ជាចៅក្រមជំនុំជម្រះ។

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកែប។

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកែប។

**តុលាការ**

-**បានឃើញ**: ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៧ អ.យ.យ ចុះថ្ងៃទី២០៣០ ខែមេសា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកែប។

-**បានឃើញ**: ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៨ អ.យ.យ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកែប។

-**បានឃើញ**: ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ១៥/២២ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកែប។

-**បានឃើញ**: ចំណារចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកែប។

-**បានឃើញ**: ដីកាសម្រេចដាក់រឿងជំនុំជម្រះ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកែប។

-**បានឃើញ**: ការផ្តល់ដំណឹងពីកាលបរិច្ឆេទនៃសវនាការតាមមាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤២ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២ ដែលមាន៖



Scanned with CamScanner

## ជនជាប់ចោទ

ឈ្មោះ [redacted] MARK ROBERT ភេទប្រុស អាយុ ៦២ឆ្នាំ ជនជាតិអូស្ត្រាលី សញ្ជាតិ អូស្ត្រាលី កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតប្រទេសអូស្ត្រាលី មានទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ឳពុកឈ្មោះ [redacted] COUTIELAS (ស) ម្តាយឈ្មោះ [redacted] BORG (ស) កម្រិតវប្បធម៌ អនុបណ្ឌិត ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន៖ ធ្លាប់ជាប់ពន្ធនាគារចំនួន ០២ឆ្នាំ ០៦ខែ នៅក្នុងពន្ធនាគារខេត្តព្រះសីហនុ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** និងធ្លាប់ជាប់ពន្ធនាគារនៅពន្ធនាគារខេត្តកំពត ០៧ខែ ពីបទ **ប្រើប្រាស់ថ្នាំញៀន**។

ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទៈ លួច (ម៉ូតូ) ប្រព្រឹត្តនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

## មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-លោក [redacted] ជាសមាជិកប្រតិភូគណៈមេធាវីប្រចាំខេត្តកែប និងជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] MARK ROBERT ។

## ដើមបណ្តឹងរដ្ឋប្បវេណី

-ឈ្មោះ [redacted] JACQUES JEAN MARIE ភេទប្រុស អាយុ៨០ឆ្នាំ ជនជាតិបារាំង មុខរបរ ទេសចរណ៍ អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ឳពុកឈ្មោះ MADEC "ស" ម្តាយឈ្មោះ LEGAREC "ស" ប្តីឈ្មោះ SUZANNE "ស" ។

## អ្នកបកប្រែភាសា

-លោក [redacted] សុភា ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ជាអ្នកបកប្រែឲ្យជនជាប់ចោទ។

## អង្គហេតុនៃបណ្តឹងចោទប្រកាន់

កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ១២ និង ៣០នាទី ថ្ងៃត្រង់ មានករណីលួច (ម៉ូតូ) មួយបានកើតឡើង បង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] MARK ROBERT បានធ្វើការលួចម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] JACQUES JEAN MARIE ដែលបានចតទុកនៅកន្លែងទូ ATM ស្ថិតនៅចំណុចតំបន់ឆ្នេរលេខទឹក ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ សង្កាត់កែប ក្រុងកែប ខេត្តកែប ក្រោយកើតហេតុជនរងគ្រោះបានធ្វើការដាក់ពាក្យបណ្តឹងទៅកាន់អធិការនគរបាលក្រុងកែប ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

កិច្ចជំនុំជម្រះបានចាប់ផ្តើម ដោយចៅក្រមជំនុំជម្រះបានប្រកាសបើកសវនាការ និងបានឲ្យក្រឡាបញ្ជីធ្វើការរាយការណ៍អំពីវត្តមានចូលរួមរបស់ភាគី ហើយសាកសួរយោបល់របស់តំណាងអយ្យការ និងមេធាវី អំពីវត្តមានភាគី និងដំណើរការរឿងក្តី ។ ជាយោបល់៖ តំណាងអយ្យការ និងមេធាវី បានជូនយោបល់ និងស្នើសុំឲ្យដំណើរកិច្ចពិភាក្សាដេញដោល ដូច្នេះចៅក្រមជំនុំជម្រះក៏បានប្រាប់ជនជាប់ចោទពីបទចោទប្រកាន់ និងបានប្រាប់អំពីសិទ្ធិរបស់ជនជាប់ចោទ ដើម្បីការពារខ្លួននាពេលជំនុំជម្រះ ៖

-ជនជាប់ចោទឈ្មោះ [redacted] MARK ROBERT បានឆ្លើយបញ្ជាក់ថា៖ ខ្ញុំទទួលស្គាល់បទចោទប្រកាន់។ ខ្ញុំពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយសារតែខ្ញុំបានយកម៉ូតូរបស់គាត់៖ ព្រោះខ្ញុំអត់មាន

លុយធ្វើដំណើរទៅស្ថានទូត។ ខ្ញុំបានឃើញម៉ូតូគេមួយគ្រឿង ម៉ាកហុងដា ពណ៌ខៀវ មិនចាំស្លាកលេខ គេបានចតទុកចោល និងមានសោរនៅជាមួយផង ខ្ញុំក៏បានជិះមកផ្ទះជួលរបស់ខ្ញុំ និងបានរៀបចំឥវ៉ាន់ទៅទីក្រុងភ្នំពេញ ក៏ត្រូវបានសមត្ថកិច្ចចាប់ខ្លួនតែម្តង។ ខ្ញុំយកម៉ូតូគេនេះមិនមែនយកទៅលក់យកលុយទេ ខ្ញុំគ្រាន់តែយកជិះទៅស្ថានទូត ដើម្បីអោយស្ថានទូតជួយរកដំណោះស្រាយរឿងជនអន្តោប្រវេសន៍ រួចហើយខ្ញុំនឹងជិះម៉ូតូមកកែបវិញ ពេលនោះខ្ញុំមិនមានលុយជិះឡានក្រុង ទើបខ្ញុំលួចម៉ូតូគេទៅ តែត្រូវសមត្ថកិច្ចឃាត់ខ្លួន។ ខ្ញុំចង់ទៅប្រទេសរបស់ខ្ញុំវិញ។ ខ្ញុំមិនស្គាល់ម្ចាស់ម៉ូតូនោះទេ ខ្ញុំយកម៉ូតូរបស់គេដើម្បីជិះទៅរកស្ថានទូតអូស្ត្រាលីអោយជួយខ្លួនដើម្បីបានទៅប្រទេសអូស្ត្រាលីវិញ។ ខ្ញុំបាទមិនបានដឹងថា អំពើដែលខ្ញុំប្រព្រឹត្តមានបទល្មើសនោះទេ។ ពេលសមត្ថកិច្ចចាប់ខ្លួនបានដកហូត ទូរស័ព្ទពីរគ្រឿង ឡេបថប់មួយ លុយខ្មែរបីម៉ឺនរៀល កាតអេធីអឹមមួយ កាតវ៉ាក់សាំង កូវីដមួយ។

-លោកមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសួរជនជាប់ចោទ ហើយជនជាប់ចោទបានឆ្លើយថា៖ ខ្ញុំចង់ទៅប្រទេសអូស្ត្រាលី បើមានឱកាសខ្ញុំនឹងទៅប្រទេសអូស្ត្រាលីវិញ។ ខ្ញុំមិនបានលួចម៉ូតូរបស់ខ្មែរទេ ខ្ញុំលួចម៉ូតូរបស់ជនជាតិបរទេស ខ្ញុំមិនដឹងថាការយកម៉ូតូរបស់គេជិះនៅប្រទេសខ្មែរមានបទល្មើសនោះទេ។ ពីមុនខ្ញុំមិនដែរលួចរបស់របរអ្វីនោះទេ ហើយខ្ញុំយកម៉ូតូគេជិះតែពីរបីថ្ងៃ ខ្ញុំនិងយកម៉ូតូមកឲ្យគេវិញ ខ្ញុំមិនមានគោលបំណងយកទៅលក់នោះទេ។

-អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ដែលមានខ្លឹមសារថា៖ ខ្លួនជាម្ចាស់កម្មសិទ្ធិលើម៉ូតូម៉ាក HONDATA ពណ៌ខៀវ ស្លាកលេខ កំពត 1H-6225។ មុនកើតហេតុខ្លួនកំពុងតែជិះម៉ូតូទៅដកលុយនៅម្តុំមាត់ទឹកឆ្នេរកែប ទូអេធីអឹមមួយកន្លែង ខ្លួនក៏បានពន្លត់ម៉ូតូតែមិនបានដកសោរម៉ូតូនោះទេ រួចហើយខ្លួនក៏ចូលទៅដកលុយ។ ស្រាប់តែខ្លួនចេញមកវិញ មិនបានឃើញម៉ូតូខ្លួន ដែលចតទុកចោលនៅមុខទូអេធីអឹមនោះទេ។ ពេលនោះខ្លួនក៏បានទៅប្រាប់ប៉ូលីស ដែលមានវត្តមាននៅក្បែរទូអេធីអឹមនោះ។ ប៉ូលីសបានប្រាប់ថា មានឃើញបុរសម្នាក់ជិះទៅបាត់ហើយ ដោយបុរសដែលជិះនោះ ប៉ូលីសមានឃើញស្នាមសាក់លើខ្លួន ស្មានតែជាមិត្តភក្តិរបស់ខ្លួន។ បន្ទាប់មកខ្លួនក៏តេទូរស័ព្ទទៅមិត្តស្រីរបស់ខ្លួនប្រាប់ថា បាត់ម៉ូតូហើយ ពេលទទួលបានដំណឹងនេះរួច មិត្តស្រីរបស់ខ្លួនក៏បានប្តឹងទៅសមត្ថកិច្ចឲ្យជួយអន្តរាគមន៍។ មួយសន្ទុះក្រោយមកប៉ូលីសក៏បានរកឃើញម៉ូតូដែលខ្លួនបានបាត់នោះ និងចាប់ខ្លួនជនដែលបានលួចម៉ូតូខ្លួនបានផងដែរ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ[redacted]សុភី ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ដែលមានខ្លឹមសារថា៖ ខ្លួនជាម្ចាស់ផ្ទះជួល ដែលបានជួលឲ្យបុរសជនជាតិអូស្ត្រាលីម្នាក់ អាយុប្រហែល៦២ឆ្នាំ សម្រាប់ស្នាក់នៅមួយរយៈពេលខ្លី ប្រហែលជាពីរទៅបីសប្តាហ៍ប៉ុណ្ណោះ ដោយគាត់បានឲ្យប្រាក់សម្រាប់ជួលជាមុន ទើបខ្លួនហ៊ានជួលឲ្យគាត់សម្រាប់ស្នាក់នៅ។ បុរសជនជាតិអូស្ត្រាលីនោះ នៅពេលដែលមកជួលផ្ទះខ្លួនដើម្បីស្នាក់នៅខ្លួន ពុំដែលឃើញបុរសនោះមានម៉ូតូសម្រាប់ជិះនោះទេ គឺពេលគាត់មកជួលផ្ទះនោះ ខ្លួនឃើញមានតែខ្លួនគាត់តែម្នាក់ឯង និងឥវ៉ាន់នៅក្នុងវ៉ាលីរបស់គាត់តែប៉ុណ្ណោះ។ ស្រាប់តែកាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ វេលាម៉ោងប្រហែល០២ និង៤០នាទី រសៀល ខ្លួនបានឃើញបុរសជនជាតិអូស្ត្រាលីនោះជិះម៉ូតូធំ ម៉ាក HONDA TA 200 ពណ៌ខៀវ ស្លាកលេខ កំពត1H-6225 ជិះមកផ្ទះជួលរបស់ខ្លួន ហើយបុរសជនជាតិអូស្ត្រាលីនោះ ក៏បានលើកឥវ៉ាលីរបស់គាត់ដាក់លើម៉ូតូ។ ឃើញដូច្នេះ ខ្លួនក៏បានសួរថា (តើលោករៀបចំឥវ៉ាន់ទៅណាដែរ) ស្រាប់តែបុរសជនជាតិអូស្ត្រាលីនោះឆ្លើយថា "ទៅកំពត"។ ខ្លួនពុំដឹងថាគាត់ ជួលម៉ូតូ ឬយកម៉ូតូពីណាទេ ពីព្រោះកាលគាត់មកជួលផ្ទះខ្លួន គឺគ្មានម៉ូតូទេ។ ខ្លួនសូមបញ្ជាក់ថា ពេលដែលគាត់ចេញទៅណាមកណា ខ្លួនពុំដែល

ដឹងទេ ស្រាប់តែម៉ោងប្រហែលជា០៤ និង៣០នាទី ខ្លួនក៏បានឃើញសមត្ថកិច្ច មកចុះឃាត់ខ្លួនជនជាតិអូស្ត្រាលី នោះនៅឯផ្ទះជួលរបស់ខ្លួន ទើបដឹងថា ការពិតម៉ូតូនោះបុរសជនជាតិអូស្ត្រាលី ម្នាក់នោះបានលួចពីគេ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted]ហួន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ដែលមានខ្លឹមសារថា៖ ខ្លួនជាមិត្តស្រីរបស់ជនរងគ្រោះឈ្មោះ MADEC JACQUES JEAN MARIE ដែលជាម្ចាស់កម្មសិទ្ធិលើម៉ូតូម៉ាក HONDA TA 200 ពណ៌ខៀវ ស្លាកលេខ 1H-6225 ដែលបានបាត់នោះ។ មុនពេលកើតហេតុខ្លួនកំពុងសម្រាកនៅផ្ទះស្រាប់តែម៉ោងប្រហែលជា១២នាទី រសៀល មិត្តប្រុសរបស់ខ្លួនបានតេទូរស័ព្ទមកខ្លួន ហើយបានប្រាប់ខ្លួនថា គេបានលួចម៉ូតូយកទៅបាត់ហើយ។ ឮដូច្នេះខ្លួនក៏បានទៅកន្លែងកើតហេតុនៅម្តុំទូអេជីអឹម ក្បែរឆ្នេរលេងទឹក ខេត្តកែប ហើយក៏បានប្តឹងទៅកាន់សមត្ថកិច្ចតែម្តង។ មួយសន្ទុះក្រោយមកសមត្ថកិច្ចក៏បានរកឃើញម៉ូតូនោះ និងធ្វើការឃាត់ខ្លួនជនដែលបានលួចម៉ូតូនោះតែម្តង។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយកិច្ចពិភាក្សាដេញដោលនាពេលសវនាការ បង្ហាញឲ្យឃើញថាៈ កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ១២ និង ៣០នាទី ថ្ងៃត្រង់ ដោយជនជាប់ចោទឈ្មោះ [redacted] MARK ROBERT បានលួចម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted]JACQUES JEAN MARIE ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ ពិតប្រាកដមែន ហើយបើផ្អែកអំណានចម្លើយរបស់ដើមបណ្តឹង, សាក្សី និងជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនបានយកម៉ូតូរបស់ជនរងគ្រោះ បំរុងជិះទៅភ្នំពេញថែមទៀតផង។ ក្រោយពីការសាកសួរនៅក្នុងពេលសវនាការនេះ ជនជាប់ចោទមិនមានការភ្ញាក់លើកពីទង្វើរបស់ខ្លួននោះទេ។ ដូច្នេះតំណាងអយ្យការនៅរក្សាបទចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ១៨ អ.យ.យ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ ទុកដដែល និងស្នើសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ប្រទេសកម្ពុជា។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបញ្ចប់ការពិភាក្សាដេញដោលនាពេលសវនាការ និងតាមចម្លើយសារភាពកូនក្តីរបស់ខ្ញុំបាទឃើញថាៈ កូនក្តីរបស់ខ្លួនគាត់ពិតជាបានយកម៉ូតូរបស់គេជិះពិតប្រាកដមែន តែគាត់មិនមានគោលបំណងយកទៅលក់នោះទេ គ្រាន់តែយកជិះទៅភ្នំពេញ ដើម្បីអោយស្ថានទូតរកដំណោះស្រាយបញ្ជូនគាត់ទៅប្រទេសដើមវិញ ហើយចប់ការងាររបស់គាត់ គាត់និងយកម៉ូតូមកអោយម្ចាស់ដើមវិញ ហើយការដែលយកម៉ូតូគេជិះនេះ កូនក្តីរបស់ខ្លួនមិនដឹងថា ជាបទល្មើសនោះទេ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] MARK ROBERT ស្នើសុំតុលាការសម្រេចបន្ធូរបន្ថយទោស ដើម្បីអោយកូនក្តីរបស់ខ្លួនបានឆាប់ចេញពីពន្ធនាគារ ដើម្បីទុកឱកាសគាត់បានត្រឡប់ទៅប្រទេសដើមវិញ។

## សម្តីចុងក្រោយការពារខ្លួន និងសំណូមពររបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] MARK ROBERT បានធ្វើកំណត់សម្គាល់ថា៖ សំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោស។

## សាលាដំបូង

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
-ក្រោយពីបានស្តាប់សម្តីចុងក្រោយការពារខ្លួន និងសំណូមពររបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យភស្តុតាងពាក់ព័ន្ធនានា ក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ
-ក្រោយពីបានពិនិត្យយ៉ាងល្អិតល្អន់ និងពិចារណាយ៉ាងគ្រប់ជ្រុងជ្រោយ

## សំអាងហេតុ

តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោលចំពោះមុខជាសាធារណៈ ដើម្បីស្វែងរកការពិតនៃសំណុំរឿងក្តីព្រហ្មទណ្ឌនេះ តាមរយៈការស្តាប់ចម្លើយរបស់ភាគីទាំងឡាយដែលពាក់ព័ន្ធ និងការពិនិត្យភស្តុតាងដែលបានស្វែងរកដោយមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរ តុលាការយល់ឃើញថា៖

**១.គោលការណ៍ដែនដីនៃការអនុវត្តច្បាប់**

តាមបញ្ញត្តិមាត្រា ១២ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីគោលការណ៍នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា ដោយក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**២.បណ្តឹងចោទប្រកាន់**

តំណាងអយ្យការ និងចៅក្រមស៊ើបសួរ បានដាក់ឲ្យស្ថិតក្រោមការពិនិត្យលើជនជាប់ចោទ៖

-ឈ្មោះ [redacted] MARK ROBERT ភេទប្រុស អាយុ ៦២ឆ្នាំ ជនជាតិអូស្ត្រាលី សញ្ជាតិអូស្ត្រាលី (មានអត្តសញ្ញាណដូចខាងលើ) ពីបទៈ លួច (ម៉ូតូ) ប្រព្រឹត្តនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**៣.ការវិនិច្ឆ័យចំពោះបទចោទប្រកាន់**

-តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ បានចែងថា ៖

អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

-តាមបញ្ញត្តិមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ បានចែងថា ៖

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] MARK ROBERT បានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលថា៖ ខ្លួនពិតជាបានយកម៉ូតូរបស់ជនរងគ្រោះជិះចេញពីកន្លែងកើតហេតុ ទៅបន្លប់ផ្លូវ និងបំរុងជិះយកទៅភ្នំពេញពិតប្រាកដមែន តែមិនទាន់បានជិះទៅភ្នំពេញក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] JACQUES JEAN MARIE បានឆ្លើយបញ្ជាក់នៅចំពោះចៅក្រមស៊ើបសួរថា៖ ខ្លួនបានជិះម៉ូតូម៉ាក HONDA TA 200 ពណ៌ខៀវ ស្លាកលេខកំពត1H-6225 ចតទុកចោលនៅមុខទូអេធីអឹម នៅក្បែរម្តុំផ្ទះលេងទឹក ខេត្តកែប ដោយមិនបានដកសោ ទុកចោល

ខ្លួនចេញពីដកលុយវិញ ក៏មិនឃើញម៉ូតូរបស់ខ្លួន ពេលនោះខ្លួនបានសួរទៅប៉ូលីសនៅក្បែរនោះ ប៉ូលីសបានប្រាប់ថា ឃើញមានបុរសម្នាក់ ស្គមសាក់លើខ្លួន បានជិះចេញទៅបាត់ហើយ។ ខ្លួនក៏បានតេទូរស័ព្ទប្រាប់មិត្តស្រីរបស់ខ្លួន ក្រោយមកមិត្តស្រីរបស់ខ្លួនក៏បានដាក់ពាក្យបណ្តឹងនៅអធិការនគរបាលក្រុងកែប មួយសន្ទុះក្រោយមកសមត្ថកិច្ចក៏ចាប់ខ្លួនឈ្មោះ [redacted] MARK ROBERT ដែលបានជិះម៉ូតូរបស់ខ្លួនទៅនោះ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុភី បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនជាម្ចាស់ផ្ទះជួល ដែលបានជួលឲ្យបុរសជនជាតិអូស្ត្រាលីម្នាក់។ បុរសជនជាតិអូស្ត្រាលីនោះនៅពេលដែលមកជួលផ្ទះខ្លួនដើម្បីស្នាក់នៅខ្លួនពុំដែលឃើញបុរសនោះមានម៉ូតូសម្រាប់ជិះនោះទេ ស្រាប់តែកាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ វេលាម៉ោងប្រហែល០២ និង៤០នាទី រសៀល ខ្លួនបានឃើញបុរស ជនជាតិអូស្ត្រាលីនោះជិះម៉ូតូធំ ម៉ាក HONDA TA 200 ពណ៌ខៀវ ស្លាកលេខ កំពត1H-6225 ជិះមកផ្ទះជួលរបស់ខ្លួន ហើយបុរសជនជាតិអូស្ត្រាលីនោះ ក៏បានលើកកាបូបរបស់គាត់ដាក់លើម៉ូតូ។ នៅម៉ោងប្រហែលជា០៤ និង៣០នាទី ខ្លួនក៏បានឃើញសមត្ថកិច្ច មកចុះឃាត់ខ្លួនជនជាតិអូស្ត្រាលីនោះនៅឯផ្ទះជួលរបស់ខ្លួនទើបដឹងថា ការពិតម៉ូតូនោះបុរសជនជាតិអូស្ត្រាលី ម្នាក់នោះបានលួចពីគេ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ហួន បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនជាមិត្តស្រីរបស់ជនរងគ្រោះឈ្មោះ [redacted] JACQUES JEAN MARIE ដែលជាម្ចាស់កម្មសិទ្ធិលើម៉ូតូម៉ាក HONDA TA 200 ពណ៌ខៀវ ស្លាកលេខ 1H-6225 ដែលបានបាត់នោះ។ មុនពេលកើតហេតុខ្លួនកំពុងសម្រាកនៅផ្ទះស្រាប់តែម៉ោងប្រហែលជា១២នាទី រសៀល មិត្តប្រុសរបស់ខ្លួនបានតេទូរស័ព្ទមកខ្លួន ហើយបានប្រាប់ខ្លួនថា គេបានលួចម៉ូតូយកទៅបាត់ហើយ។ ដូច្នេះខ្លួនក៏បានទៅកន្លែងកើតហេតុនៅម៉ូតូអេធីអឹម ក្បែរឆ្នេរលេងទឹក ខេត្តកែប ហើយក៏បានប្តឹងទៅកាន់សមត្ថកិច្ចតែម្តង។ មួយសន្ទុះក្រោយមកសមត្ថកិច្ចក៏បានរកឃើញម៉ូតូនោះ និងធ្វើការឃាត់ខ្លួនជនដែលបានលួចម៉ូតូនោះតែម្តង។

-យោងតាមចម្លើយរបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងសាក្សីខាងលើ គឺមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងនានាដែលបានស្វែងរកដោយមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ និងចៅក្រមស៊ើបសួរ ដែលបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា៖ ជនជាប់ចោទពិតជាបានធ្វើសកម្មភាពដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិជាម៉ូតូរបស់ជនរងគ្រោះ នៅពេលដែលជនរងគ្រោះកំពុងដកប្រាក់នៅក្នុងទូដកប្រាក់ ATM ដោយមិនបានដកសោម៉ូតូចេញ ប្រព្រឹត្តនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ និងបានជិះម៉ូតូយកទៅទុកនៅក្នុងផ្ទះជួលរបស់ខ្លួន ប្រាកដមែន ។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] MARK ROBERT ភេទប្រុស អាយុ ៦២ឆ្នាំ ជនជាតិអូស្ត្រាលី ពីបទៈ លួច (ម៉ូតូ) ប្រព្រឹត្តនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

### ៤.ការវិនិច្ឆ័យចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំ

-តំណាងអយ្យការប្តឹងសុំចៅក្រមជំនុំជម្រះ សម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] MARK ROBERT ស្នើសុំតុលាការសម្រេចបន្ធូរបន្ថយទោស ដើម្បីអោយកូនក្តីរបស់ខ្លួនបានឆាប់ចេញពីពន្ធនាគារ ដើម្បីទុកឱកាសឲ្យគាត់បានត្រឡប់ទៅប្រទេសដើមវិញ ។

-ជនជាប់ចោទបានធ្វើកំណត់សម្គាល់ខ្លីៗថា៖ សំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោស។

-តាមបញ្ញត្តិមាត្រា ៣៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា៖ សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការមានមូលដ្ឋានត្រឹមត្រូវសមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌ គប្បីតុលាការពិចារណាតាមច្បាប់ ។

-ការស្នើសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងកំណត់សម្គាល់របស់ជនជាប់ចោទខាងលើ គប្បីតុលាការពិចារណាទៅលើកាលៈទេសៈ និងស្ថានភាពជាក់ស្តែងនៃអំពើ តាមនីតិវិធីច្បាប់ជាធរមាន។

**៥.ការវិនិច្ឆ័យចំពោះសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ**

ជនជាប់ចោទឈ្មោះ [redacted] MARK ROBERT គឺជានីតិជនដែលមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ ពោលគឺពុំមានភស្តុតាងណាមួយបញ្ជាក់ថាជននេះមានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងអំពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន ស្របតាមបញ្ញត្តិមាត្រា៣៨ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

ជនជាប់ចោទមានកម្រិតវប្បធម៌ដល់ថ្នាក់អនុបណ្ឌិត ផ្នែកសន្លាក់ នៅប្រទេសអូស្ត្រាលី ដូច្នេះការយល់ដឹងរបស់ជនជាប់ចោទមានកម្រិតខ្ពស់ ដែលអាចវិនិច្ឆ័យអំពីសកម្មភាពល្មើសច្បាប់បានយ៉ាងច្បាស់លាស់ ។

**៦.ការវិនិច្ឆ័យចំពោះទោស និងរបបប្រកាសទោស**

**ក.ចំពោះទោស**

តុលាការពិចារណាលើកយកការសម្រេចទោសដាក់ពន្ធនាគារទៅលើជនជាប់ចោទ ដោយផ្អែកលើបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ មុន អំឡុងពេល និងក្រោយប្រព្រឹត្តអំពើល្មើស ដោយហេតុថា ជនជាប់ចោទពុំមានស្មារតីភ្ញាក់រលឹកទៅលើអំពើដែលខ្លួនបានប្រព្រឹត្តរួចហើយ ក៏ដូចជាពុំបានដឹងអំពីកំហុសរបស់ខ្លួននោះឡើយ ដោយលើកមូលហេតុថាខ្លួនបានលួចពីជនបរទេស មិនមែនជនជាតិខ្មែរនោះទេ ដូច្នេះតុលាការពុំលើកយកស្ថានសម្រាលទោស មកអនុវត្តលើជនជាប់ចោទ នោះទេ ។

ម៉្យាងទៀត ជនជាប់ចោទបានអះអាងថាខ្លួនធ្លាប់ជាប់ពន្ធនាគារនៅខេត្តព្រះសីហនុ និងខេត្តកំពត ប៉ុន្តែនៅដំណាក់កាលស៊ើបអង្កេត និងស៊ើបសួរ គឺពុំស្វែងរកបាននូវសាលក្រមស្ថាពរណាមួយ មកបញ្ជាក់ថាជនជាប់ចោទពិតជាធ្លាប់ត្រូវបានផ្តន្ទាទោសជាស្ថាពរដោយតុលាការ នោះឡើយ ។ ដូច្នេះ តុលាការពុំលើកយកស្ថានទម្ងន់ទោស មកអនុវត្តលើជនជាប់ចោទ ឡើយ ។

**ខ.ចំពោះរបបប្រកាសទោស**

តាមបញ្ញត្តិមាត្រា ៩៧ និងមាត្រា ៣៥៦ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា តុលាការសម្រេចយកការប្រកាសមូលទោស ដោយការផ្តន្ទាទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ទៅលើជនជាប់ចោទខាងលើ ដោយហេតុថា ជនជាប់ចោទពុំមានលទ្ធភាពក្នុងការបង់ប្រាក់ពិន័យចូលជាថវិការដ្ឋនោះឡើយ ពោលគឺ ដោយសារតែមូលហេតុពុំមានប្រាក់កាស ដើម្បីដោះស្រាយពាក់ព័ន្ធនឹងអន្តោប្រវេសន៍នៅកម្ពុជា និងដើម្បីអាចធ្វើដំណើរត្រឡប់ទៅប្រទេសកំណើតរបស់ខ្លួនវិញបាន ទើបជននេះប្រព្រឹត្តអំពើលួចម៉ូតូ ខាងលើនេះ ។

**៧.ការវិនិច្ឆ័យចំពោះវត្ថុចាប់យក**

-វត្ថុចាប់យក ដែលត្រូវបានដកហូតដោយមន្ត្រីនគរបាលយុត្តិធម៌ រួមមាន: ១.ម៉ូតូមួយគ្រឿងម៉ាក Hongda Phanten ពាក់ស្លាកលេខ កំពត1H-6225 ពណ៌ខៀវ, ២.ទូរស័ព្ទម៉ាក OPPO ពណ៌ខ្មៅមួយគ្រឿង, ៣.ផេបប្លេក ម៉ាក់សាំសុងពណ៌ខ្មៅ ០១គ្រឿង, ៤. ទូរស័ព្ទម៉ាកវីវ៉ូ ០១គ្រឿង ពណ៌ទឹកមាស (ខូចគុណភាព)

៥.លុយខ្មែរចំនួន ៣៣,០០០ (បីម៉ឺនបីពាន់) រៀល លុយដុល្លាចំនួន ០១ដុល្លា, ៦.វីសាកាលអេប៊ីអេ, ៧.កាតវ៉ាក់សាំង០១, ៨.កូនកាំបិតបត់មួយ, ៩.កាបូបដាក់សំលៀកបំពាក់ចំនួន០៣ ពណ៌ខ្មៅ និងតូចចំនួន០២ ដូចមានក្នុងកំណត់ហេតុដកហូតវត្ថុតាង ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២២ ។

-យោងតាមពាក្យស្នើសុំម៉ូតូរបស់ឈ្មោះ [redacted] JEAN MARIE ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០២២។

-យោងតាមដីកាសម្រេចប្រគល់វត្ថុចាប់យកឲ្យទៅម្ចាស់ដើមវិញលេខ ៨៨/២២ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកែប។

-តុលាការយល់ឃើញថា ចៅក្រមស៊ើបសួរបានចេញដីកាសម្រេចប្រគល់វត្ថុចាប់យកឲ្យទៅម្ចាស់ដើមវិញនូវម៉ូតូមួយគ្រឿងម៉ាក Hongda Phanten ពាក់ស្លាកលេខ កំពត1H-6225 ពណ៌ខៀវ រួចរាល់ហើយ ។ គប្បី តុលាការមិនលើកយកវត្ថុចាប់យកជាម៉ូតូខាងលើ មកសម្រេចជាថ្មីនោះទេ។

-ម្យ៉ាងវិញទៀតចំពោះវត្ថុចាប់យកដែលសមត្ថកិច្ចដកហូតពីជនជាប់ចោទនោះ ឃើញថា៖ វត្ថុទាំងនោះមិនមានជាប់ពាក់ព័ន្ធនឹងបទល្មើស ឬជាមធ្យោបាយ ឬជាផលប្រយោជន៍ដែលកើតចេញពីបទល្មើសនោះទេ។ គប្បីតុលាការសម្រេចប្រគល់វត្ថុចាប់យកទៅអោយម្ចាស់ដើមវិញ សម្រាប់ជាមធ្យោបាយធ្វើដំណើរនៅពេលអនុវត្តទោសចប់សព្វគ្រប់នៅក្នុងពន្ធនាគារ ។

**៨.ការវិនិច្ឆ័យចំពោះសំណងរដ្ឋប្បវេណី**

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] JACQUES JEAN MARIE មិនបានទាមទារសំណងរដ្ឋប្បវេណីនោះទេ គប្បីតុលាការមិនលើកយកមកពិចារណា។

## <u>**វិនិច្ឆ័យសេចក្តី**</u>

## <u>**ហេតុដូច្នេះសម្រេច**</u>

I. ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] MARK ROBERT ភេទប្រុស អាយុ ៦២ឆ្នាំ ជនជាតិអូស្ត្រាលី សញ្ជាតិអូស្ត្រាលី (មានអត្តសញ្ញាណដូចខាងលើ)

ដាក់ពន្ធនាគារកំណត់រយៈពេល **០១ (មួយ) ឆ្នាំ** គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន ។

ពីបទៈ **លួច (ម៉ូតូ)** ប្រព្រឹត្តនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៦** នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

II. ប្រគល់វត្ថុចាប់យករួមមាន៖

១.ទូរស័ព្ទម៉ាក OPPO ពណ៌ខ្មៅមួយគ្រឿង,

២.ផេបប្លេក ម៉ាក់សាំសុងពណ៌ខ្មៅ០១គ្រឿង,

៣.ទូរស័ព្ទម៉ាកវីវ៉ូ០១គ្រឿង ពណ៌ទឹកមាស (ខូចគុណភាព),

៤.លុយខ្មែរចំនួន៣៣,០០០ (បីម៉ឺនបីពាន់) រៀល លុយដុល្លាចំនួន ០១ដុល្លា,

៥.វីសាកាលអេប៊ីអេ,

៦.កាតវ៉ាក់សាំង០១,

៧.កាបូបដាក់សំលៀកបំពាក់ចំនួន០៣ ពណ៌ខ្មៅ និងតូចចំនួន០២

៨.កូនកាំបិតបត់មួយ

ទៅឈ្មោះ [redacted] MARK ROBERT (មានអត្តសញ្ញាណដូចខាងលើ) ដែលជាម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃ១៤ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] MARK ROBERT និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] JACQUES JEAN MARIE ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខានិងត្រា-[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខានិងត្រា[redacted]

---

**-បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម-**

ថ្ងៃព្រហស្បតិ៍ ១រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកែប ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]